PRUDENTIAL
ព្រូដិនសល ធានារ៉ាប់រងអាយុជីវិត

# ខ និង លក្ខខណ្ឌ

**អត្ថប្រយោជន៍បន្ថែមចំនួន 2000 ដុល្លារ ក្នុងករណីទទួលមរណភាពដោយសារជំងឺកូវីដ 19 (COVID-19)**

១. ខ និងលក្ខខណ្ឌ របស់បណ្ណសន្យារ៉ាប់រងដែលលោកអ្នកបានជាវ នៅតែមានសុពលភាព និងត្រូវប្រើប្រាស់ជាឯកសារគោល ប្រសិនបើមានភាពខុសគ្នារវាង ខ និងលក្ខខណ្ឌទាំងនោះ និង ខ និងលក្ខខណ្ឌ របស់អត្ថប្រយោជន៍បន្ថែមនៅផ្នែកខាងក្រោមនេះ។

២. "កូវីដ 19 (COVID-19)" សំដៅទៅលើករណីដូចដែលបានឱ្យនិយមន័យ ដោយអង្គការសុខភាពពិភពលោក និងបញ្ជាក់ដោយរបាយការណ៍ដែលចេញពីមន្ទីរពេទ្យជំនាញ ឬ គ្រូពេទ្យជំនាញ ដែលបានចុះបញ្ជីត្រឹមត្រូវ ឬ មន្ទីរពេទ្យមានសមត្ថកិច្ចចាត់តាំងដោយរាជរដ្ឋាភិបាល។

៣. នេះជាអត្ថប្រយោជន៍ ក្នុងករណីទទួលមរណភាព ដែលផ្តល់បន្ថែមដោយក្រុមហ៊ុនព្រូដិនសលកម្ពុជា ដោយមិនតម្រូវឱ្យបង់បុព្វលាភធានារ៉ាប់រងបន្ថែមឡើយ សម្រាប់អ្នកត្រូវបានធានារ៉ាប់រងទាំងអស់ស្ថិតនៅក្រោមបណ្ណសន្យារ៉ាប់រងដែលមានសុពលភាព។ ក្នុងករណីទទួលមរណភាពដែលស្របតាម ខ និង លក្ខខណ្ឌ ចាប់ពីថ្ងៃទី 01 ខែមីនា ឆ្នាំ2020 រហូតដល់ ថ្ងៃទី 30 ខែមេសា ឆ្នាំ2020 ក្រុមហ៊ុនព្រូដិនសលកម្ពុជា នឹងផ្តល់ជាសំណងអត្ថប្រយោជន៍បន្ថែមចំនួន 2000 ដុល្លារអាមេរិក។

៤. យើងខ្ញុំនឹងមិនធ្វើការទូទាត់សំណងបន្ថែមនេះជូនឡើយ ចំពោះបណ្ណសន្យារ៉ាប់រងដែលចាប់ផ្តើមមានសុពលភាពពីថ្ងៃទី 01 ខែមីនា ឆ្នាំ2020 រហូតដល់ ថ្ងៃទី 30 ខែមេសា ឆ្នាំ2020 និងបណ្ណសន្យារ៉ាប់រងដែលបន្តសុពលភាពឡើងវិញ ប្រសិនបើក្រុមហ៊ុនរកឃើញថា អ្នកត្រូវបានធានារ៉ាប់រងមានជំងឺកូវីដ 19 (COVID-19) ឬ ប្រសិនបើរោគសញ្ញានៃជំងឺនេះកើតមានឡើងមុន ឬ នៅត្រឹមកាលបរិច្ឆេទមានសុពលភាពនៃបណ្ណសន្យារ៉ាប់រង ឬកាលបរិច្ឆេទមានសុពលភាពនៃការបន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញ ដោយយកកាលបរិច្ឆេទណាមួយចុងក្រោយគេ។

៥. អត្ថប្រយោជន៍នេះនឹងត្រូវបានទូទាត់ជូន តែម្តងប៉ុណ្ណោះសម្រាប់អ្នកត្រូវបានធានារ៉ាប់រងម្នាក់ ដោយមិនគិតពីចំនួនបណ្ណសន្យារ៉ាប់រងដែលមានឡើយ។

៦. យើងខ្ញុំរក្សាសិទ្ធិក្នុងការកែប្រែ ខ និង លក្ខខណ្ឌនៃការការពារបន្ថែមនេះដោយពុំចាំបាច់ជូនដំណឹងជាមុន។នៅក្នុងករណីដែលមានវិវាទណាមួយពាក់ព័ន្ធនឹងអត្ថប្រយោជន៍បន្ថែមចំនួន 2000ដុល្លារអាមេរិកនេះយើងខ្ញុំជាអ្នកមានសិទ្ធិនៅក្នុងការធ្វើការសម្រេចចិត្តចុងក្រោយ។